# ព្រះរាជក្រម

នស/រកម/០៥០៩/០០៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឆែក ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៥ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

/.

ROYAUME DU CAMBODGE

Downloaded from http://www.khmerlaws.com

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋឆែក ស្តីពីការជំរុញនិងការការពារទៅវិញទៅមកនូវការវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឆែកស្តីពីការជំរុញនិងការការពារទៅវិញទៅមកនូវការវិនិយោគ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែឧសភាឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៩០៥.៥១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ :៤៧/៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញៈថ្ងៃទី២៧ ខែឧសភាឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជំអាន

៣/៣

Downloaded from http://www.khmerlaws.com

# កិច្ចព្រមព្រៀង
# រវាង
# រដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាល នៃ សាធារណរដ្ឋ ឆែក
# ស្តីពី
# ការជំរុញ និង ការការពារទៅវិញទៅមកនូវការវិនិយោគ

៚៚៚

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណៈរដ្ឋ ឆែក (ចាប់ពីពេលនេះតទៅហៅថា "ភាគីជាប់កិច្ចសន្យា")

ដោយមានគោលបំណង អភិវឌ្ឍន៍នូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដើម្បីផលប្រយោជន៍ទៅវិញទៅមករវាងរដ្ឋទាំងពីរ

ដោយមានចេតនាបង្កើត និងរក្សាបាននូវលក្ខខណ្ឌអំណោយផលសំរាប់ការវិនិយោគនៃអ្នកវិនិយោគរបស់រដ្ឋមួយនៅលើទឹកដី នៃរដ្ឋមួយទៀត និង

ដោយទទួលស្គាល់ថា ការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគតាមរយៈកិច្ចព្រមព្រៀងនេះ លើកទឹកចិត្តឱ្យមានការផ្តួចផ្តើមធុរកិច្ចនានា ក្នុងវិស័យនេះ

បានព្រមព្រៀងគ្នាដូចតទៅ :

## មាត្រាទី ១
## និយមន័យ

ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ :

១- ពាក្យ " **វិនិយោគទុន** "មានរូមបញ្ចូលនូវរាល់ទ្រព្យសម្បត្តិដែលបានវិនិយោគភ្ជាប់ទៅនឹងសកម្មភាពសេដ្ឋកិច្ចទាំងឡាយ ធ្វើឡើងដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីម្ចាស់ផ្ទះ និងរួមមានជាអាទិ៍ តែពុំកំណត់តែត្រឹមអ្វីដូចមានរៀបរាប់ខាងក្រោមនេះឡើយ:

/ក/ ចលនទ្រព្យ និង អចលនទ្រព្យ រួមទាំងកម្មសិទ្ធិដទៃទៀត ដូចជា ការបញ្ចាំ សិទ្ធិនៃការដកហូត ឬការសន្យា

Downloaded from http://www.khmerlaws.com

/ខ/ ភាគហ៊ុន ហ៊ុន ប័ណ្ណបំណុល របស់ក្រុមហ៊ុន និងទ្រង់ទ្រាយផ្សេងៗទៀតនៃការរួមចំណែកនៅក្នុងសហគ្រាស

/គ/ ការទាមទារប្រាក់ ឬការទាមទារនូវការអនុវត្តកិច្ចសន្យាដែលមានតំលៃហិរញ្ញវត្ថុទាក់ទងទៅនឹងការវិនិយោគ

/ឃ/ សិទ្ធិកម្មសិទ្ធិបញ្ញា ដែលមានន័យថាជា ពាណិជ្ជសញ្ញា ប៉ាតង់ គំរោងប្លង់ឧស្សាហកម្ម ក្បួនខ្នាតបច្ចេកវិជ្ជា ស្លាដែយល់ដឹង ការសម្គាល់ធុរកិច្ច ពាណិជ្ជនាម និងកិត្តិនាមពាណិជ្ជកម្មដែលទាក់ទងដល់ការវិនិយោគ

/ង/ សិទ្ធិដែលបានទទួលដោយច្បាប់ ឬតាមរយៈកិច្ចសន្យា និងអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតដែលយោងដោយច្បាប់ រាប់បញ្ចូលទាំងសម្បទានក្នុងការស្វែងរក ការទាញយកផល ការដាំដុះ ឬការធ្វើអាជីវកម្មធនធានធម្មជាតិ

ការប្រែប្រួលទ្រង់ទ្រាយនៃទ្រព្យសម្បត្តិណាមួយ ដែលត្រូវបានវិនិយោគ មិនមានផលប៉ះពាល់ដល់លក្ខណៈសម្បត្តិនៃការវិនិយោគឡើយ ។

២- ពាក្យ " **អ្នកវិនិយោគ** " មានន័យថា រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត :

/ក/ ពាក្យថា "រូបវន្តបុគ្គល" មានន័យថា រូបវន្តបុគ្គលណាមួយដែលមានសញ្ជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ដោយអនុលោមទៅតាមច្បាប់របស់ភាគីជាប់កិច្ចសន្យានោះ ។

/ខ/ ពាក្យថា " នីតិបុគ្គល " មានន័យថា ចំពោះភាគីនីមួយៗ គឺអង្គភាពដែលស្ថិតនៅក្រោម ឬបង្កើតឡើង ដោយអនុលោម និងទទួលស្គាល់ជានីតិបុគ្គល ស្របតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យា ដែលមានទីស្នាក់ការ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានោះ ។

៣- ពាក្យ " **ចំណូលផល** " មានន័យថា :ចំណូលបានមកពីការវិនិយោគ និងមានជាអាទិ៍ដែលមិនកំណត់ត្រឹមនេះឡើយ នូវប្រាក់ចំណេញ ការប្រាក់ទាក់ទងទៅនឹងប្រាក់កម្ចី ផលកំរៃ ភាគហ៊ុន ភាគលាភ កំរៃឈ្នួល ឬកំរៃ ។

៤- ពាក្យ " **ទឹកដី** " មានន័យថា :

/ក/ ចំពោះព្រះរាជាណាចក្រកម្ពុជា គឺ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានតំបន់សមុទ្ររាប់បញ្ចូលទាំងបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងព្រំដែនខាងក្រៅនៃបាតសមុទ្រ ហើយដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិគ្រប់គ្រងអធិបតេយ្យភាព ឬ

Downloaded from http://www.khmerlaws.com

កាតព្វកិច្ចគ្រប់គ្រងតាមផ្លូវច្បាប់ ដោយអនុលោមទៅតាមច្បាប់ជាតិ ដែលត្រូវស្របទៅនឹងច្បាប់អន្តរជាតិ ។

/ខ/ ចំពោះសាធារណរដ្ឋឆែក គឺទឹកដីនៃសាធារណរដ្ឋឆែក ទីដែលសាធារណរដ្ឋឆែកអនុវត្តអធិបតេយ្យភាព សិទ្ធិត្រួតត្រា និងកាតព្វកិច្ចគ្រប់គ្រង ស្របទៅនឹងច្បាប់អន្តរជាតិ ។

## មាត្រាទី ២
## ការជំរុញ និង ការការពារការវិនិយោគ

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវលើកទឹកចិត្ត និងបង្កើតភាពអនុគ្រោះដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ក្នុងការធ្វើវិនិយោគលើទឹកដីរបស់ខ្លួន ហើយទទួលស្គាល់ការវិនិយោគនោះដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ។

២- ការវិនិយោគ របស់អ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលបានការយល់ព្រមគ្រប់ពេលវេលា នូវប្រព្រឹត្តិកម្មដោយត្រឹមត្រូវ និងស្មើភាព និងត្រូវបានទទួលនូវកិច្ចការពារ និងមានសុវត្ថិភាពពេញលេញ នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

## មាត្រាទី ៣
## ប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មនៃប្រជាជាតិដែលទទួលនូវការអនុគ្រោះបំផុត

១- ភាគីជាប់កិច្ចសន្យានីមួយ ៗ ត្រូវផ្តល់នូវការយល់ព្រមក្នុងទឹកដីរបស់ខ្លួន លើការធ្វើវិនិយោគ និងទិន្នផលរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តិកិច្ចដោយត្រឹមត្រូវ និងយុត្តិធម៌ និងមិនតិចជាងអ្វីដែល ខ្លួនបានផ្តល់អោយការវិនិយោគ និងទិន្នផលរបស់អ្នកវិនិយោគជាជនជាតិខ្លួន ឬការវិនិយោគ និង ទិន្នផលរបស់អ្នកវិនិយោគនៃតតីយរដ្ឋណាមួយនោះឡើយ ឱ្យតែប្រព្រឹត្តិកម្មនោះមានលក្ខណៈអនុគ្រោះច្រើន ចំពោះអ្នកវិនិយោគដែលពាក់ព័ន្ធ ។

២- ភាគីជាប់កិច្ចសន្យា ត្រូវផ្តល់ការយល់ព្រមក្នុងទឹកដីរបស់ខ្លួនទៅឱ្យអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតទាក់ទងនឹងការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលបាន ឬការចាត់ចែងនៃការវិនិយោគនូវប្រព្រឹត្តិកម្ម ដែលត្រឹមត្រូវ និងយុត្តិធម៌ មិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យទៅឱ្យអ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃតតីយរដ្ឋណាមួយនោះឡើយ ឱ្យតែប្រព្រឹត្តកម្មនោះ មានលក្ខណៈអនុគ្រោះច្រើន ចំពោះអ្នកវិនិយោគដែលពាក់ព័ន្ធ ។

Downloaded from http://www.khmerlaws.com

៣- បញ្ញត្តិនៃប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្មនៃប្រជាជាតិដែលទទួលនូវការអនុគ្រោះបំផុតនៃមាត្រានេះ មិនត្រូវបានយកទៅអនុវត្ត ចំពោះផលប្រយោជន៍ ដែលភាគីជាប់កិច្ចសន្យាម្ខាងត្រូវទទួលបាន ដោយអនុលោមទៅតាមកាតព្វកិច្ចរបស់ខ្លួន ក្នុងនាមជាសមាជិកនៃសហព័ន្ធគយ សហព័ន្ធសេដ្ឋកិច្ច ឬ សហព័ន្ធរូបិយវត្ថុ តំបន់ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរីនោះឡើយ ។

៤- ភាគីជាប់កិច្ចសន្យាយល់ច្បាស់ពីកាតព្វកិច្ចនៃភាគីជាប់កិច្ចសន្យា ដែលជាសមាជិកនៃ សហព័ន្ធគយ សហព័ន្ធសេដ្ឋកិច្ច ឬសហព័ន្ធរូបិយវត្ថុ តំបន់ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរីនេះ មានរួមបញ្ចូលផងដែរ អំពីកាតព្វកិច្ចដែលកំណត់ឡើងដោយកិច្ចព្រមព្រៀងអន្តរជាតិ ឬ កិច្ចព្រមព្រៀងបក្សាប័ននៃសហព័ន្ធគយ សហព័ន្ធសេដ្ឋកិច្ច ឬសហព័ន្ធរូបិយវត្ថុ តំបន់ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរីនោះ ។

៥- បញ្ញត្តិនៃមាត្រានេះ មិនត្រូវបានបកស្រាយថា ជាការចាប់បង្ខំភាគីជាប់កិច្ចសន្យាម្ខាង ឱ្យបើកទូលាយដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ឬ ដល់ការវិនិយោគ ឬទិន្នផលនៃអ្នកវិនិយោគនោះ នូវផលប្រយោជន៍នៃប្រព្រឹត្តិកម្មណាមួយ ភាពអនុគ្រោះ ឬបុព្វសិទ្ធិ ដែលបានបើកទូលាយដោយភាគីជាប់កិច្ចសន្យាមុននោះ ដោយផ្អែកទៅនឹងកិច្ចព្រមព្រៀងអន្តរជាតិ ឬការសំរបសំរួលណាមួយ ដែលទាក់ទងទាំងស្រុង ឬជាសំខាន់ទៅនឹងកិច្ចការពន្ធដារនោះឡើយ ។

## មាត្រាទី ៤
## សំណងសំរាប់ការខាតបង់

១- នៅពេលដែលការវិនិយោគធ្វើឡើងដោយអ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យាណាមួយទទួលរងនូវការខាតបង់ ដែលបណ្តាលមកពីសង្គ្រាម ឬជំលោះអាវុធ ការប្រកាសប្រទេសជាតិស្ថិតក្នុងភាពអាសន្ន បដិវត្ត កុប្បកម្ម ភាពចលាចលស៊ីវិល ឬហេតុការណ៍ប្រហាក់ប្រហែល នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត អ្នកវិនិយោគនោះត្រូវតែបានទទួលការយល់ព្រមពីភាគីជាប់កិច្ចសន្យា ដែលជាម្ចាស់ទឹកដីនោះនូវប្រព្រឹត្តិកម្ម ដូចជាការធ្វើឱ្យដូចដើមវិញ ការប៉ះប៉ូវសំណង ឬ ដំណោះស្រាយណាមួយផ្សេងទៀត មិនតិចជាងភាពអនុគ្រោះ ដែលភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះបានផ្តល់ឱ្យអ្នកវិនិយោគរបស់ជនជាតិខ្លួន ឬអ្នកវិនិយោគនៃតតិយជនណាមួយនោះឡើយ ។

២- ដោយមិនឱ្យមានផលប៉ះពាល់ដល់កថាខណ្ឌទី១ នៃមាត្រានេះ អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងដែលស្ថិតនៅក្នុងហេតុការណ៍ណាមួយផ្អែកលើកថាខណ្ឌនេះ បានរងនូវការខាតបង់នៅក្នុងទឹកដី

Downloaded from http://www.khmerlaws.com

នៃភាគី ជាប់កិច្ចសន្យាម្ខាងទៀត ដែលបណ្តាលមកពី :

/ក/ ការរឹបអូសទ្រព្យសម្បត្តិ ដោយកំលាំងទ័ព ឬអាជ្ញាធរនៃភាគីម្ចាស់ផ្ទះ ឬ

/ខ/ ការបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួន ដោយកំលាំងទ័ព ឬដោយអាជ្ញាធរនៃភាគីម្ចាស់ផ្ទះ ដែលមិនមែនជាមូលហេតុនៃសកម្មភាពប្រយុទ្ធគ្នា ដែលមិនស្ថិតក្នុងស្ថានភាពចាំបាច់ទេនោះនឹងត្រូវទទួលបាននូវសំណងតាមស្ថានភាពដើមវិញ ឬសំណងគ្រប់ចំនួន នៃការខាតបង់ដែលបង្កឡើងនាពេលរឹបអូស ឬបច្ច័យនៃការបំផ្លាញទ្រព្យសម្បត្តិ ។ ការទូទាត់សំណង ត្រូវធ្វើដោយរូបិយបណ្ណដែលអាចផ្ទេរ និងប្តូរបានដោយសេរី និងពុំមានការពន្យាពេលឡើយ ។

## មាត្រាទី ៥
## ការដកហូត

១- ការវិនិយោគនៃអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាណាមួយមិនត្រូវបានធ្វើជាតូបនីយកម្ម មិនត្រូវបានដកហូត ឬប្រកាន់យកនូវវិធានការណ៍ ដែលមានឥទ្ធិពលស្មើគ្នាទៅនឹងការធ្វើជាតូនីយកម្ម ឬការដកហូត ( នៅទីនេះនិយាយសំដៅលើការដកហូត ) នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយលើកលែងតែសំរាប់គោលបំណងជាផលប្រយោជន៍សាធារណៈ ។ ការដកហូតត្រូវប្រព្រឹត្តិទៅតាមនីតិវិធីនៃច្បាប់ លើមូលដ្ឋានគ្មានការរើសអើង និង ភ្ជាប់ជាមួយនូវការទូទាត់សំណងយ៉ាងឆាប់រហ័សគ្រប់ចំនួននិងជាក់ស្តែង ។ សំណងត្រូវមានទឹកប្រាក់ស្មើនឹងតំលៃនៃការវិនិយោគ ដែលបានដកហូត នៅមុនពេលដែលការដកហូត ឬព្រឹត្តិការណ៍នៃការដកហូតបានផ្សាយចេញជាសាធារណៈ ។ សំណងត្រូវរួមបញ្ចូលផងដែរនូវការប្រាក់គិតចាប់ពីថ្ងៃដកហូត ដោយមិនមានការពន្យាពេល មានប្រសិទ្ធិភាពដំណើការ និងត្រូវធ្វើដោយរូបិយបណ្ណដែលអាចផ្ទេរ និងប្តូរបានដោយសេរី ។

២- អ្នកវិនិយោគដែលទទួលរងនូវការដកហូត មានសិទ្ធិធ្វើការពិនិត្យឡើងវិញជាប្រញាប់ តាមរយៈតុលាការ ឬអាជ្ញាធរឯករាជ្យនៃភាគីជាប់កិច្ចសន្យាដែលការវិនិយោគបានធ្វើនៅក្នុងទឹកដីនោះ ចំពោះករណីនិងការវាយតំលៃនៃការវិនិយោគរបស់ខ្លួន ស្របតាមគោលការណ៍កំណត់នៃមាត្រានេះ ។

Downloaded from http://www.khmerlaws.com

## មាត្រាទី ៦
## ការផ្ទេរ

១- ដោយមិនឱ្យមានផលប៉ះពាល់ដល់វិធានការដែលបានអនុម័តដោយសហគមន៍អឺរ៉ុប ភាគីជាប់កិច្ចសន្យា ត្រូវធានាការទូទាត់ដែលត្រូវផ្ទេរទាក់ទងទៅនឹងការវិនិយោគ និងទិន្នផល ។ ការផ្ទេរនឹងត្រូវធ្វើឡើង ដោយរូបិយប័ណ្ណដែលអាចប្តូរបានដោយសេរី ដោយគ្មានការដាក់កំហិត និងគ្មានការពន្យាពេល ។ ការផ្ទេរនេះរាប់បញ្ចូលនូវទឹកប្រាក់ជាពិសេស តែមិនកំណត់ដាច់ខាតតែត្រឹមនេះទេ :

/ក/ ដើមទុន និងទឹកប្រាក់បន្ថែម ដើម្បីទ្រទ្រង់ ឬបង្កើនវិនិយោគ

/ខ/ ប្រាក់ចំណេញ ការប្រាក់ ភាគលាភ និងចំណូលចំពោះមុខផ្សេងៗ

/គ/ មូលនិធិសំរាប់ទូទាត់ប្រាក់កម្ចី

/ឃ/ កំរៃសួយសារ ឬថ្លៃឈ្នួល

/ង/ ប្រាក់ដែលបានមកពីការលក់ ការជំរះបញ្ជីនៃការវិនិយោគ

/ច/ ចំណូលនៃបុគ្គលិក មកពីបរទេស ដែលបំរើការងារ និងអនុញ្ញាតឱ្យធ្វើការងារ ដែលភ្ជាប់ទៅនឹងការវិនិយោគ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

២- សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ អត្រាប្តូរប្រាក់ គឺគិតទៅតាមអត្រាទីផ្សារនៃអាជីវកម្ម ចំពោះមុខនាថ្ងៃផ្ទេរ លើកលែងតែមានការព្រមព្រៀងផ្សេងទៀត ។

៣- ការផ្ទេរត្រូវបានចាត់ទុកថានឹងប្រព្រឹត្តទៅដោយ " មិនមានការពន្យារពេល " ដូចអត្ថន័យនៃកថាខ័ណ្ឌ (១) នៃមាត្រានេះ ក្នុងរយៈពេលចាំបាច់ជាធម្មតា សំរាប់ការបំពេញបែបបទផ្ទេរ ។

## មាត្រា ៧
## ឧបាទេសកម្ម

១- ក្នុងករណីដែលភាគីជាប់កិច្ចសន្យាមួយ ឬភ្នាក់ងារដែលបានតែងតាំងបានផ្តល់នូវការទូទាត់ទៅឱ្យអ្នកវិនិយោគរបស់ខ្លួនក្រោមកិច្ចធានារ៉ាប់រងដែលខ្លួនបានយល់ព្រមចំពោះការវិនិយោគនៅក្នុងទឹកដីនៃ ភាគីជាប់កិច្ចសន្យាម្ខាងទៀត ភាគីម្ចាស់ផ្ទះត្រូវទទួលស្គាល់:

/ក/ ការផ្ទេរនូវសិទ្ធិ អំណាច ឬការទាមទាររបស់អ្នកវិនិយោគ ស្របតាមច្បាប់ ឬអនុលោមតាមការធ្វើពាណិជ្ជកម្មស្របច្បាប់នៅក្នុងប្រទេសនោះ ជូនភាគីជាប់កិច្ចសន្យា ដែលបានផ្ទេរ ឬភ្នាក់ងារដែលបាន

Downloaded from http://www.khmerlaws.com

ទទួលការចាត់តាំងផងដែរ ។

/ខ/ ថាភាគីជាប់កិច្ចសន្យារបស់អ្នកវិនិយោគ ឬភ្នាក់ងាររបស់ភាគីនេះ មានសិទ្ធិ ដោយផ្អែកតាមការធ្វើឧបាទេសកម្ម ដើម្បីអនុវត្តនូវសិទ្ធិអំណាច និងការទាមទារនៃអ្នកវិនិយោគនោះ ហើយក៏ទទួលខុសត្រូវចំពោះកាតព្វកិច្ចដែលទាក់ទងទៅនឹងការវិនិយោគផងដែរ ។

២- ឧបាទេសកម្ម នូវសិទ្ធិអំណាច និងការទាមទារ មិនត្រូវហួសពីសិទ្ធិ និងអំណាចនៃអ្នកវិនិយោគដែលបានទទួលពីដំបូងនោះឡើយ ។

## មាត្រា ៨

## ដំណោះស្រាយជំទាស់ រវាងភាគីជាប់កិច្ចសន្យា និងអ្នកវិនិយោគ នៃ ភាគីជាប់កិច្ចសន្យាម្ខាងទៀត

១- វិវាទណាមួយដែលកើតឡើងរវាងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ជាមួយភាគីជាប់កិច្ចសន្យាម្ខាងទៀតពាក់ព័ន្ធទៅនឹងការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានោះ ត្រូវធ្វើការចរចារវាងភាគីដែលមានវិវាទនោះ ។

២- ប្រសិនបើវិវាទរវាងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាង ជាមួយភាគីជាប់កិច្ចសន្យាម្ខាងទៀតនោះ មិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែ ចាប់ពីថ្ងៃដែលករណីវិវាទត្រូវបានលើកឡើង អ្នកវិនិយោគមានសិទ្ធិបញ្ជូនករណីនោះ តាមការជ្រើសរើសរបស់ខ្លួន ដើម្បីសុំការដោះស្រាយទៅ:

/ក/ តុលាការមានសមត្ថកិច្ច ឬតុលាការរដ្ឋបាលនៃភាគី ជាប់កិច្ចសន្យាដែលជាភាគីមានជំលោះ ឬ

/ខ/ មជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ ( ICSID ) ដែលអនុវត្តនូវបទប្បញ្ញត្តិ ផ្អែកតាមអនុសញ្ញាស្តីពីដំណោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋនានា ដែលបានចុះហត្ថលេខានៅទីក្រុងវ៉ាស៊ីនតោន កាលពីថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៦៥ ប្រសិនបើភាគីជាប់កិច្ចសន្យាទាំងពីរជាភាគីនៃអនុសញ្ញានេះ ឬ

/គ/ អាជ្ញាកណ្តាលតែម្នាក់ ឬតុលាការអាជ្ញាកណ្តាលអន្តរជាតិពិសេស AD HOC ដែលបានបង្កើតឡើងតាមវិធាននៃច្បាប់អាជ្ញាកណ្តាលរបស់គណៈកម្មការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ( UNCITRAL ) ។ ភាគីមានវិវាទ អាចយល់ព្រមធ្វើការផ្លាស់ប្តូរវិធានទាំងនោះជាលាយលក្ខណ៍អក្សរ ។

Downloaded from http://www.khmerlaws.com

៣- តុលាការអាជ្ញាកណ្តាលត្រូវសំរេចក្តីលើមូលដ្ឋានច្បាប់ ដោយយកចិត្តទុកដាក់ទៅលើប្រភពនៃច្បាប់ តាមឋានានុក្រមដូចតទៅ:

- បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងផ្សេងទៀតដែលមានការពាក់ព័ន្ធរវាងភាគីជាប់កិច្ចសន្យា
- ច្បាប់ជាធរមាននៃភាគីជាប់កិច្ចសន្យាដែលពាក់ព័ន្ធ
- បញ្ញត្តិនៃកិច្ចព្រមព្រៀងពិសេស ពាក់ព័ន្ធដល់ការវិនិយោគ
- គោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ។

៤- ការសំរេចរបស់អាជ្ញាកណ្តាលគឺជាការសំរេចចុងក្រោយ ដែលភាគីមានវិវាទទាំងពីរត្រូវតែគោរព ហើយត្រូវបានអនុវត្តដោយស្របទៅតាមនីតិវិធីតុលាការក្នុងស្រុក ។

## មាត្រា ៩
## ការដោះស្រាយវិវាទ រវាងភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យាដែលទាក់ទងដល់ការបកស្រាយ ឬការអនុវត្តន៍កិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយតាមការចរចា នៅតាមលទ្ធភាពដែលអាចធ្វើបាន ។

២- ប្រសិនបើវិវាទមិនអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែទេនោះ វិវាទត្រូវស្នើឡើងដោយភាគីជាប់កិច្ចសន្យាណាមួយ ទៅតុលាការអាជ្ញាកណ្តាលស្របតាមបញ្ញត្តិនៃមាត្រានេះ ។

៣- តុលាការអាជ្ញាកណ្តាលនោះ ត្រូវបានបង្កើតឡើងទៅតាមករណីផ្ទាល់ខ្លួនតាមបែបបទដូចតទៅ: ក្នុងរយៈពេលពីរខែនៃការទទួលបាននូវសំណើដើម្បីសុំឱ្យមានការធ្វើអាជ្ញាកណ្តាល ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវតែងតាំងសមាជិកអាជ្ញាកណ្តាលម្នាក់ ។
បន្ទាប់មកសមាជិកទាំងពីរនេះត្រូវជ្រើសរើសជនជាតិម្នាក់នៃតតីយរដ្ឋ ដែលបានការយល់ព្រមពីភាគីជាប់កិច្ចសន្យាទាំងពីរដើម្បីធ្វើជាប្រធានតុលាការអាជ្ញាកណ្តាល (ចាប់ពីពេលនេះទៅហៅថាប្រធាន) ។ ប្រធាននេះ ត្រូវបានតែងតាំងអោយហើយស្រេចក្នុងរយៈពេល បី ខែ គិតពីថ្ងៃ ដែលបានតែងតាំងសមាជិកទាំងពីររូប ។

៤- ប្រសិនបើក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌទី៣នៃមាត្រានេះ ការតែងតាំងមិនអាចធ្វើបាន

Downloaded from http://www.khmerlaws.com

បាន សំណើតែងតាំងអាចស្នើទៅប្រធានតុលាការអន្តរជាតិដើម្បីសុំឱ្យធ្វើការតែងតាំងដ៏ចាំបាច់នេះ ។ ក្នុងករណី ប្រធានតុលាការនោះ ជាជនជាតិ នៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារងារនេះបាន អនុប្រធានតុលាការត្រូវបានអញ្ជើញដើម្បីធ្វើការតែងតាំងដ៏ចាំបាច់នេះ ។ ប្រសិនបើអនុប្រធានតុលាការនោះ ជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារនេះបានទៀត សមាជិករបស់តុលាការយុត្តិធម៌អន្តរជាតិ ដែលមានឋានៈខ្ពស់បន្ទាប់ដែលមិនមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ នឹងត្រូវបានអញ្ជើញដើម្បីទទួលការតែងតាំងដ៏ចាំបាច់នេះ ។

៥- តុលាការអាជ្ញាកណ្តាលត្រូវសំរេចក្តីទៅតាមរយៈការបោះឆ្នោតយកសំឡេងភាគច្រើន ។ការសំរេចក្តីបែបនេះភាគីវិវាទត្រូវតែគោរពតាម ។ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលរ៉ាប់រងចេញនូវសោហ៊ុយចំណាយសំរាប់អាជ្ញាកណ្តាលរបស់ខ្លួន និងសំរាប់អ្នកតំណាងស្របច្បាប់របស់ខ្លួនក្នុងដំណើការដំណោះស្រាយវិវាទរបស់អាជ្ញាកណ្តាល ។ តម្លៃចំណាយសំរាប់ប្រធានតុលាការ និងចំណាយដែលនៅសេសសល់ទៀត ត្រូវតែជាបន្ទុកស្មើគ្នា ដែលភាគីទាំងពីរត្រូវទទួលរ៉ាប់រង ។ តុលាការអាជ្ញាកណ្តាលត្រូវកំណត់នូវ នីតិវិធីការងារសំរាប់កិច្ចដំណើរការរបស់ខ្លួន ។

## មាត្រា ១០
## ការអនុវត្តន៍បណ្តាវិធានផ្សេងៗ និងការសន្យាពិសេស

១- ប្រសិនបើនៅពេលណាដែលបញ្ហាមួយត្រូវបានគ្រប់គ្រងព្រមគ្នា ដោយកិច្ចព្រមព្រៀងនេះ និងដោយកិច្ចព្រមព្រៀងអន្តរជាតិមួយទៀត ដែលភាគីជាប់សន្យាទាំងពីរជាភាគីនោះ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះដែលរារាំងមិនឱ្យភាគីជាប់កិច្ចសន្យាណាមួយ ឬអ្នកវិនិយោគរបស់ខ្លួនដែលបានធ្វើការវិនិយោគនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតក្នុងការទទួលបាននូវអត្ថប្រយោជន៍នៃវិធានណាមួយដែលមានភាពអនុគ្រោះសំរាប់ករណីរបស់គេនោះឡើយ ។

២- ប្រសិនបើប្រព្រឹត្តកម្មដែលបានយល់ព្រមផ្តល់ដោយភាគីជាប់កិច្ចសន្យាម្ខាងជូនអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ឬបទប្បញ្ញត្តិពិសេសផ្សេងទៀតនៃកិច្ចសន្យា ដែលមានភាពអនុគ្រោះជាងអ្វីដែលបានយល់ព្រមដោយកិច្ចព្រមព្រៀងនេះ ភាពអនុគ្រោះដែលប្រសើរជាងនោះ ត្រូវតែបានទទួលការយល់ព្រមផងដែរ ។

Downloaded from http://www.khmerlaws.com

## មាត្រាទី ១១
## អត្ថប្រយោជន៍នៃសន្តិសុខពិសេស

១- មិនមានអ្វីក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីរារាំងភាគីជាប់កិច្ចសន្យាណាមួយ ក្នុងការប្រកាន់យកនូវសកម្មភាព ដែលគេពិចារណាថា ចាំបាច់ត្រូវប្រកាន់យកសំរាប់ការពារផលប្រយោជន៍នៃសន្តិសុខពិសេសរបស់គេនោះឡើយ:

/ក/ ទាក់ទងទៅនឹងបទល្មើសឧក្រិដ្ឋ ឬព្រហ្មទណ្ឌ

/ខ/ ទាក់ទងនឹងការរត់ពន្ធអាវុធ គ្រាប់រំសេវ និងសម្ភារៈបំរើសង្គ្រាម និងការធ្វើអាជីវកម្មលើទំនិញ សម្ភារៈបរិក្ខារ សេវាកម្ម និងបច្ចេកវិទ្យា ដទៃទៀត ដែលបានអនុវត្តដោយផ្ទាល់ ឬ ដោយប្រយោលក្នុងគោលបំណងធ្វើការផ្គត់ផ្គង់ឱ្យកំលាំងយោធា ឬការបង្កើតសន្តិសុខដទៃទៀត ។

/គ/ មានទំនាក់ទំនងអន្តរជាតិក្នុងពេលមានសង្គ្រាម ឬករណីប្រកាសអាសន្នដទៃទៀត ឬ

/ឃ/ទាក់ទងទៅនឹងការអនុវត្តគោលនយោបាយរបស់ជាតិ ឬកិច្ចព្រមព្រៀងអន្តរជាតិ ក្នុងការគោរពនូវគោលការណ៍មិនសាយភាយអាវុធនុយក្លេអ៊ែរ ឬ ឧបករណ៍បំផ្ទុះនុយក្លេអ៊ែរដទៃទៀត ឬ

/ង/ដោយយោលទៅតាមកាតព្វកិច្ចនៃធម្មនុញ្ញសហប្រជាជាតិ ស្តីពីការថែរក្សានូវសន្តិភាព និងសន្តិសុខអន្តរជាតិ ។

២- អត្ថប្រយោជន៍នៃសន្តិសុខពិសេសរបស់ភាគីជាប់កិច្ចសន្យា អាចរួមបញ្ចូលផងដែរនូវអត្ថប្រយោជន៍ដែលកើតមានមកពីភាពជាសមាជិករបស់ខ្លួននៅក្នុង សហភាព គយ សេដ្ឋកិច្ច ឬហិរញ្ញវត្ថុ ទីផ្សាររួម ឬតំបន់ពាណិជ្ជកម្មសេរី ។

## មាត្រាទី ១២
## ទំហំវិសាលភាពគ្របដណ្តប់ នៃ កិច្ចព្រមព្រៀង

បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ នឹងអនុវត្ត ចំពោះការវិនិយោគនាពេលអនាគត ដែលធ្វើឡើងដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងនៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និងការវិនិយោគមានស្រាប់ដែលកំពុងដំណើរការស្របតាមច្បាប់នៃភាគីជាប់កិច្ចសន្យា នៅថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ ទោះបីជាយ៉ាងនេះក៏ដោយ បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ នឹងមិនអនុវត្តទៅចំពោះការតវ៉ាទាមទារដែលកើតមាន ឬ ការតវ៉ាដែលបានដោះស្រាយរួច មុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ ។

Downloaded from http://www.khmerlaws.com

## មាត្រា ១៣

## ការចូលជាធរមាន ថេរវេលា និងការបញ្ចប់

១- ភាគីជាប់កិច្ចសន្យាម្ខាង ត្រូវជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត នូវការបំពេញរួចរាល់ហើយ អំពីនីតិវិធីដែលតម្រូវដោយច្បាប់របស់ខ្លួន ដើម្បីដាក់ឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន ក្រោយរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងជាលើកទីពីរ ។

២- កិច្ចព្រមព្រៀងនេះ មានសុពលភាពរយៈពេលដប់ឆ្នាំ ។ បន្ទាប់ពីរយៈនោះ កិច្ចព្រមព្រៀងនៅមានសុពលភាពរហូតដល់ផុតកំណត់រយៈពេលដប់ពីរខែ គិតចាប់ពីថ្ងៃដែលភាគីជាប់កិច្ចសន្យាម្ខាងបានជូនដំណឹងទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត ជាលាយលក្ខណ៍អក្សរអំពីគោលបំណងរបស់ខ្លួនក្នុងការបញ្ចប់កិច្ចព្រមព្រៀង ។

៣- ចំពោះការវិនិយោគដែលបានធ្វើមុនការបញ្ចប់សុពលភាពនៃកិច្ចព្រមព្រៀងនេះ បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ នឹងបន្តមានសុពលភាពរយៈពេលដប់ឆ្នាំ បន្ទាប់ពីថ្ងៃបញ្ចប់សុពលភាព ។

ដើម្បីជាសាក្សីនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ ដែលបានទទួលសិទ្ធិអំណាចគ្រប់គ្រាន់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើនៅ ...ភ្នំពេញ............ ថ្ងៃទី 12 ...ខែឧសភា... ឆ្នាំ 2008 ជាភាសាខ្មែរ ភាសាឆែក ភាសាអង់គ្លេស អត្ថបទទាំងអស់នេះមានតំលៃគតិយុត្តិស្មើៗគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នានោះ អត្ថបទជាភាសាអង់គ្លេស ត្រូវបានយកមកធ្វើជាសំអាង ។

| | |
|---|---|
| តំណាងរដ្ឋាភិបាល | តំណាងរដ្ឋាភិបាល |
| នៃព្រះរាជាណាចក្រកម្ពុជា | នៃសាធារណរដ្ឋឆែក |
| ចាន់ សារុន | Ivan Hitek |
| ............................................ | ............................................ |

Downloaded from http://www.khmerlaws.com

# AGREEMENT

# BETWEEN THE GOVERNMENT OF THE KINGDOM OF CAMBODIA AND THE GOVERNMENT OF THE CZECH REPUBLIC FOR THE PROMOTION AND RECIPROCAL PROTECTION OF INVESTMENTS

The Government of the Kingdom of Cambodia and Government of the Czech Republic (hereinafter referred to as the "Contracting Parties"),

Desiring to develop economic co-operation to the mutual benefit of both States,

Intending to create and maintain favourable conditions for investments of investors of one State in the territory of the other State, and

Conscious that the promotion and reciprocal protection of investments in terms of the present Agreement stimulates the business initiatives in this field,

Have agreed as follows:

## Article I
## Definitions

For the purposes of this Agreement:

1. The term "investment" shall comprise every kind of asset invested in connection with economic activities by an investor of one Contracting Party in the territory of the other Contracting Party in accordance with the laws and regulations of the latter and shall include, in particular, though not exclusively:

   /a/ movable and immovable property as well as any other property rights, such as mortgages, liens or pledges;

   /b/ shares, stocks and debentures of companies or any other form of participation in a company;

Downloaded from http://www.khmerlaws.com

/c/ claims to money or to any performance under contract having a financial value associated with an investment;

/d/ intellectual property rights, which mean trade marks, patents, industrial designs, technical processes, know-how, trade secrets, trade names and goodwill associated with an investment;

/e/ any right conferred by laws or under contract and any licenses and permits pursuant to laws, including the concessions to search for, extract, cultivate or exploit natural resources.

Any alteration of the form in which assets are invested shall not affect their character as investment.

2. The term "investor" shall mean any natural or legal person who invests in the territory of the other Contracting Party.

/a/ The term "natural person" shall mean any natural person having the nationality of either Contracting Party in accordance with its laws.

/b/ The term "legal person" shall mean, with respect to either Contracting Party, any entity incorporated or constituted in accordance with, and recognized as legal person by its laws, having the seat in the territory of one of the Contracting Parties.

3. The term "returns" shall mean amounts yielded by an investment and in particular, though not exclusively, includes profits, interest related to loans, capital gains, shares, dividends, royalties or fees.

4. The term "territory" shall mean:

/a/ in respect of the Kingdom of Cambodia, the territory of the Kingdom of Cambodia including the territorial sea as well as those maritime areas adjacent to the outer limit of territorial sea over which the Kingdom of Cambodia has jurisdiction or sovereign rights pursuant to national law which must correspond to international law.

/b/ in respect of the Czech Republic, the territory of the Czech Republic over which it exercises sovereignty, sovereign rights and jurisdiction in accordance with international law;

## Article 2

### Promotion and Protection of Investments

1. Each Contracting Party shall encourage and create favourable conditions for investors of the other Contracting Party to make investments in its territory and shall admit such investments in accordance with its laws and regulations.

Downloaded from http://www.khmerlaws.com

2. Investments of investors of either Contracting Party shall at all times be accorded fair and equitable treatment and shall enjoy full protection and security in the territory of the other Contracting Party.

**Article 3**

**National and Most-Favoured-Nation Treatment**

1. Each Contracting Party shall in its territory accord to investments and returns of investors of the other Contracting Party treatment which is fair and equitable and not less favourable than that which it accords to investments and returns of its own investors or to investments and returns of investors of any third State, whichever is more favourable.

2. Each Contracting Party shall in its territory accord to investors of the other Contracting Party, as regards management, maintenance, use, enjoyment or disposal of their investment, treatment which is fair and equitable and not less favourable than that which it accords to its own investors or to investors of any third State, whichever is more favourable.

3. The National Treatment and Most-Favoured-Nation Treatment provisions of this Article shall not apply to advantages accorded by a Contracting Party pursuant to its obligations as a member of a customs, economic, or monetary union, a common market or a free trade area.

4. The Contracting Party understands the obligations of a Contracting Party as a member of a customs, economic, or monetary union, a common market or a free trade area to include obligations arising out of an international agreement or reciprocity agreement of that customs, economic, or monetary union, common market or free trade area.

5. The provisions of this Agreement shall not be construed so as to oblige one Contracting Party to extend to the investors of the other Contracting Party, or to the investments or returns of such investors, the benefit of any treatment, preference or privilege which may be extended by the former Contracting Party by virtue of any international agreement or arrangement relating wholly or mainly to taxation.

**Article 4**

**Compensation for Losses**

1. Where investments of investors of either Contracting Party suffer losses owing to war, armed conflict, a state of national emergency, revolt, insurrection, riot or other similar events in the territory of the other Contracting Party, such investors shall be accorded by the latter Contracting Party treatment, as regards restitution, indemnification,

Downloaded from http://www.khmerlaws.com

compensation or other settlement, not less favourable than that which the latter Contracting Party accords to its own investors or to investors of any third State.

2. Without prejudice to paragraph 1 of this Article, investors of one Contracting Party who in any of the events referred to in that paragraph suffer losses in the territory of the other Contracting Party resulting from:

/a/ requisitioning of their property by the forces or authorities of the latter Contracting Party, or

/b/ destruction of their property by the forces or authorities of the latter Contracting Party which was not caused in combat action or was not required by the necessity of the situation,

shall be accorded restitution or just and adequate compensation for the losses sustained during the period of the requisitioning or as a result of the destruction of the property. Resulting payments shall be freely transferable in a freely convertible currency without delay.

**Article 5**

**Expropriation**

1. Investments of investors of either Contracting Party shall not be nationalized, expropriated or subjected to measures having effect equivalent to nationalization or expropriation (hereinafter referred to as "expropriation") in the territory of the other Contracting Party except for a public purpose. The expropriation shall be carried out under due process of law, on a non-discriminatory basis and shall be accompanied by provisions for the payment of prompt, adequate and effective compensation. Such compensation shall amount to the value of the investment expropriated immediately before expropriation or impending expropriation became public knowledge, shall include interest from the date of expropriation, shall be made without delay, be effectively realizable and be freely transferable in a freely convertible currency.

2. The investor affected shall have a right to prompt review by a judicial or other independent authority of that Contracting Party in which territory the investment has been made, of his or its case and of the valuation of his or its investment in accordance with the principles set out in this Article.

**Article 6**

**Transfers**

1. Without prejudice to measures adopted by the European Community, the Contracting Parties shall guarantee the transfer of payments related to investments and returns. The

Downloaded from http://www.khmerlaws.com

transfers shall be made in a freely convertible currency, without any restriction and undue delay. Such transfers shall include in particular, though not exclusively:

/a/ capital and additional amounts to maintain or increase the investment;

/b/ profits, interest, dividends and other current income;

/c/ funds in repayment of loans;

/d/ royalties or fees;

/e/ proceeds of sale or liquidation of the investment;

/f/ the earnings of personnel engaged from abroad who are employed and allowed to work in connection with an investment in the territory of the other Contracting Party.

2. For the purpose of this Agreement, exchange rate shall be the prevailing market rate for current transactions at the date of transfer, unless otherwise agreed.

3. Transfers shall be considered to have been made "without any undue delay" in the sense of paragraph (1) of this Article when they have been made within the period normally necessary for the completion of the transfer.

## Article 7

## Subrogation

1. If a Contracting Party or its designated agency makes a payment to its own investors under a guarantee it has accorded in respect of an investment in the territory of the other Contracting Party, the latter Contracting Party shall recognize:

/a/ the assignment, whether under the law or pursuant to a legal transaction in that country, of any right or claim by the investor to the former Contracting Party or its designated agency, as well as,

/b/ that the former Contracting Party or its designated agency is entitled by virtue of subrogation to exercise the rights and enforce the claims of that investor and shall assume the obligations related to the investment.

2. The subrogated rights or claims shall not exceed the original rights or claims of the investor.

Downloaded from http://www.khmerlaws.com

## Article 8

### Settlement of Investment Disputes between a Contracting Party and an Investor of the other Contracting Party

1. Any dispute which may arise between an investor of one Contracting Party and the other Contracting Party in connection with an investment in the territory of that other Contracting Party shall be subject to negotiations between the parties to the dispute.

2. If any dispute between an investor of one Contracting Party and the other Contracting Party cannot be thus settled within six months of the date when the request for the settlement has been submitted, the investor shall be entitled to submit the case, at his choice, for settlement to:

   /a/ the competent court or administrative tribunal of the Contracting Party which is the party to the dispute; or

   /b/ the International Centre for Settlement of Investment Disputes (ICSID) having regard to the applicable provisions of the Convention on the Settlement of Investment Disputes between States and Nationals of other States opened for signature at Washington D.C. on 18 March 1965, in the event both Contracting Parties shall have become a party to this Convention; or

   /c/ an arbitrator or international ad hoc arbitral tribunal established under the Arbitration Rules of the United Nations Commission on International Trade Law (UNCITRAL). The parties to the dispute may agree in writing to modify these Rules.

3. The arbitral tribunal shall decide on the basis of the law, taking into account the sources of law in the following sequence:

   - the provisions of this Agreement, and other relevant Agreements between the Contracting Parties;
   - the law in force of the Contracting Party concerned;
   - the provisions of special agreements relating to the investment;
   - the general principles of international law.

4. The arbitral awards shall be final and binding on both parties to the dispute and shall be enforceable in accordance with the domestic legislation.

Downloaded from http://www.khmerlaws.com

## Article 9

### Settlement of Disputes between the Contracting Parties

1. Disputes between the Contracting Parties concerning the interpretation or application of this Agreement shall, if possible, be settled through consultations or negotiations.

2. If the dispute cannot be thus settled within six months, it shall upon the request of either Contracting Party be submitted to an Arbitral Tribunal in accordance with the provisions of this Article.

3. The Arbitral Tribunal shall be constituted for each individual case in the following way. Within two months of the receipt of the request for arbitration, each Contracting Party shall appoint one member of the Tribunal. These two members shall then select a national of a third State who on approval of the two Contracting Parties shall be appointed Chairman of the Tribunal (hereinafter referred to as the "Chairman"). The Chairman shall be appointed within three months from the date of appointment of the other two members.

4. If within the periods specified in paragraph 3 of this Article the necessary appointments have not been made, a request may be made to the President of the International Court of Justice to make the necessary appointments. If he happens to be a national of either Contracting Party, or if he is otherwise prevented from discharging the said function, the Vice-President shall be invited to make the necessary appointments. If the Vice-President also happens to be a national of either Contracting Party or is prevented from discharging the said function, the member of the International Court of Justice next in seniority who is not a national of either Contracting Party shall be invited to make the necessary appointments.

5. The Arbitral Tribunal shall reach its decision by a majority of votes. Such decision shall be binding. Each Contracting Party shall bear the cost of its own arbitrator and its representation in the arbitral proceedings; the cost of the Chairman and the remaining costs shall be borne in equal parts by both Contracting Parties. The Arbitral Tribunal shall determine its own procedure.

## Article 10

### Application of Other Rules and Special Commitments

1. Where a matter is governed simultaneously both by this Agreement and by another international agreement to which both Contracting Parties are parties, nothing in this Agreement shall prevent either Contracting Party or any of its investors who own investments in the territory of the other Contracting Party from taking advantage of whichever rules are more favourable to his case.

2. If the treatment to be accorded by one Contracting Party to investors of the other Contracting Party in accordance with its laws and regulations or other specific

Downloaded from http://www.khmerlaws.com

provisions of contracts is more favourable than that accorded by the Agreement, the more favourable shall be accorded.

### Article 11

### Essential Security Interests

1. Nothing in this Agreement shall be construed to prevent any Contracting Party from taking any actions that it considers necessary for the prevention of its essential security interests,

   /a/ relating to criminal or penal offences;

   /b/ relating to traffic in arms, ammunition and implements of war and transactions in other goods, materials, services and technology undertaken directly or indirectly for the purpose of supplying a military or other security establishment;

   /c/ taken in time of war or other emergency in international relations, or

   /d/ relating to the implementation of national policies or international agreements respecting the non-proliferation of nuclear weapons or other nuclear explosive devices or

   /e/ in pursuance of its obligations under the United Nations Charter for the maintenance of international peace and security.

2. A Contracting Party's essential security interests may include interests deriving from its membership in a customs, economic, or monetary union, a common market or a free trade area.

### Article 12

### Applicability of this Agreement

The provisions of this Agreement shall apply to future investments made by investors of one Contracting Party in the territory of the other Contracting Party, and also to the investments existing in accordance with the laws of the Contracting Parties on the date this Agreement came into force. However, the provisions of this Agreement shall not apply to claims arising out of events, which occurred, or to claims, which had been settled, prior to its entry into force.

Downloaded from http://www.khmerlaws.com

**Article 13**

**Entry into Force, Duration and Termination**

1. Each of the Contracting Parties shall notify the other of the completion of the procedures required by its law for bringing this Agreement into force. This Agreement shall enter into force on the thirtieth day after the date of the second notification.

2. This Agreement shall remain in force for a period of ten years. Thereafter, it shall remain in force until the expiration of a twelve month period from the date either Contracting Party notifies the other in writing of its intention to terminate the Agreement.

3. In respect of investments made prior to the termination of this Agreement, the provisions of this Agreement shall continue to be effective for a period of ten years from the date of termination.

**IN WITNESS WHEREOF**, the undersigned duly authorized have signed this Agreement.

DONE in duplicate at Phnom Penh on 12 May.......... 2008 in the Khmer, Czech and English languages, all texts being equally authentic. In case of any divergence of interpretation the English text shall prevail.

| FOR THE GOVERNMENT OF THE KINGDOM OF CAMBODIA | FOR THE GOVERNMENT OF THE CZECH REPUBLIC |
|---|---|
| Keat Chhon | Ivan Hotěk |

Downloaded from http://www.khmerlaws.com